**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ : ១៤១៤/១៣ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោក ក្លាំង យ៉ក តំណាងសហគមន៍ជនជាតិដើមភាគតិច ព្រៅ**

**ភូមិទំពួនរឹងតូច ឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិទំពួនរឹងតូច ឃុំតាវែងក្រោម ស្រុកតាវែង

**យោង :** - លិខិតចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិទំពួនរឹងតូច របស់លោក ក្លាំង យ៉ក តំណាងសហគមន៍។

- លិខិតលេខ ៣៥៨/១៣ ល.អ.ខ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិទំពួនរឹងតូច របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិទំពួនរឹងតូច របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិទំពួនរឹងតូច ឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរីតាមសំណើ ។ សហគមន៍ជនជាតិដើមភាគតិច ព្រៅ ភូមិទំពួនរឹងតូច អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាម គោលនយោបាយ ច្បាប់ បទបញ្ជា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ជា សុផារ៉ា**

*ចម្លងជូន*

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងបរិស្ថាន
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងទេសចរណ៍

"ដើម្បីជូនជ្រាប"

-សាលាខេត្តរតនគិរី
-មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី

"ដើម្បីមុខការ"

-ឯកសារ - កាលប្បវត្តិ ,

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្សី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com